# ប្រវត្តិព្រះពុទ្ធសាសនា

## ដែលផ្សាយចូលមកប្រទេសកម្ពុជា

# THE HISTORY OF BUDDHISM IN CAMBODIA

ចំណេះដឹងគ្រប់វិនាទី



រៀបរៀងដោយលោក សម-ញាណ
ប្រធានពុទ្ធិកសមាគមកម្ពុជរដ្ឋ

ក្នុងឱកាសបុណ្យ២៥០០វស្សានៃព្រះពុទ្ធសាសនា

by
SAM-NHEAN
President of the Buddhist Association in Cambodia

1957

បណ្ណាល័យ No 33
២១០.
៦៩
www.facebook.com/7khmer
Fb page : Entertainment And Knowledge

២១០.៦៩

# ប្រវត្តិព្រះពុទ្ធសាសនា

## ដែលផ្សាយចូលមកប្រទេសកម្ពុជា

BUDDHIST INSTITUTE LIBRARY
៦៦៩០/០២

រៀបរៀងដោយលោក សម-ញាណ

ប្រធានពុទ្ធិកសមាគមកម្ពុជរដ្ឋ

ក្នុងឱកាសបុណ្យ ២៥០០ វស្សានៃពុទ្ធសាសនា

www.facebook.com/7khmer
Fb page : Entertainment And Knowledge

យើងសូមអរគុណដល់ក្រុមឃោសនាការអាមេរិកាំង
នៅប្រទេសកម្ពុជាដែលជួយចាត់ចែងសៀវភៅនេះ
ឲ្យបានសម្រេចឡើង

ស ម ញា ណ

បំនួន ១០.០០០ ក្បាល

បោះពុម្ព ផ្សាយនៅប្រទេសកម្ពុជា-ភ្នំពេញ

ថ្ងៃទី ១ ខែឧសភា ឆ្នាំ ១៩៥៧

www.facebook.com/7khmer
Fb page : Entertainment  And Knowledge

# សេចក្ដីប្រារព្ធ

ក្នុងឱកាសធ្វើបុណ្យនៃពុទ្ធសករាជ ២៥០០ វស្សានេះ គណៈកម្មាធិការនាយកនៃពុទ្ធិកសមាគមកម្ពុជរដ្ឋបានសុំឲ្យខ្ញុំរៀបរៀងប្រវត្តិព្រះពុទ្ធសាសនាដ៏សង្ខេប នៃប្រទេសកម្ពុជា ដើម្បីចែកប្រគេនជូនដល់អស់លោកជនជាតិខ្មែរយើង ដែលបាននិមន្ត–អញ្ជើញមកធ្វើបុណ្យ ព.ស. ២៥០០ វស្សា ។

ព្រមទាំងអស់លោកជាពុទ្ធិកជនបរទេស ដែលបានមករួបរួម ធ្វើបុណ្យជាមួយនឹងយើងក្ដី ឬក៏ដោយមានសទ្ធាជួបចិត្ត ធ្វើបុណ្យនេះនៅក្នុងប្រទេសរបស់អស់លោកក្ដី ។ ក្នុងសៀវភៅនេះ ពុទ្ធិកសមាគមកម្ពុជរដ្ឋ មានបំណងចង់ឲ្យអស់លោកពុទ្ធបរិស័ទជ្រាប៖

១ – អំពីហេតុ ដែលព្រះពុទ្ធសាសនាផ្សាយចូលមកប្រទេសកម្ពុជានេះព្រោះអ្វី? ពីឆ្នាំណាមក?

២ – ប្រទេសកម្ពុជា គ្រានោះមានទ្រង់ទ្រាយដូចម្ដេច?

៣ – ព្រះថេរអង្គណាខ្លះ ដែលនិមន្តផ្សាយព្រះពុទ្ធសាសនាជាដំបូង?

៤ – ធុរៈរបស់ព្រះពុទ្ធសាសនា មានប៉ុន្មានយ៉ាង?

៥ – ពាក្យឱវាទ ដែលចេញពីគន្ថធុរៈដកស្រង់យ៉ាងខ្លី មានប៉ុន្មានយ៉ាង? បានសេចក្ដីដូចម្ដេចខ្លះ?

៦ – បទពិចារណាក្នុងវិបស្សនាធុរៈ ដកស្រង់យ៉ាងខ្លី មានប៉ុន្មានយ៉ាង?

៧ – ព្រះពុទ្ធសាសនា តាំងនៅបានព្រោះអាស្រ័យហេតុអ្វី?

www.facebook.com/7khmer
Fb page : Entertainment And Knowledge

កាលបើអស់លោកជ្រាបនូវរឿងខាងលើនេះហើយ ខ្ញុំសង្ឃឹមថា មុខជាអស់លោកនឹករលឹកចំពោះគុណនៃព្រះថេរៈទាំងឡាយ ដែលនិមន្តមកផ្សាយព្រះពុទ្ធសាសនាក្នុងប្រទេសកម្ពុជា យើងជាដំបូង ព្រមទាំងនឹករលឹកចំពោះព្រះពុទ្ធអង្គផង ។

ពិធីធ្វើបុណ្យដ៏ឧឡារិករំឭកគុណព្រះពុទ្ធអង្គ ដោយប្រជុំប្រមូលចិត្តគំនិតគ្នាដូច្នេះអាចរិតចំណងមេត្រីភាព រវាងយើងទាំងអស់គ្នាទៅ ។

ម្យ៉ាងទៀត ខ្ញុំបានសុំឲ្យលោក អាំង-ឃាវ មន្ត្រីរងអនុពន្ធវប្បធម៌ នៃក្រុម-ឃោសនាការស្ថានឯកអគ្គរដ្ឋទូតអាមេរិកាំងនៅភ្នំពេញ ប្រែរឿងនេះជាភាសាអង់គ្លេសជាប់ជាមួយ ដើម្បីនូវអស់លោកពុទ្ធបរិស័ទបរទេស ជ្រាបនូវរឿងខាងលើនេះផង ។

ធ្វើនៅក្រុងភ្នំពេញ នៅថ្ងៃព្រហស្បតិ៍ ៤ រោច ខែចេត្រ ឆ្នាំរកានព្ស័ក-ព.ស. ២៥០០ ត្រូវនឹងថ្ងៃទី ១៨ ខែមេសា គ.ស. ១៩៥៧ ។

សម - ញាណ

ប្រធានពុទ្ធិកសមាគមកម្ពុជរដ្ឋ

www.facebook.com/7khmer
Fb page : Entertainment And Knowledge

# ១ - អំពីហេតុដែលព្រះពុទ្ធសាសនាផ្សាយចូលមកប្រទេសកម្ពុជា ព្រោះអ្វី ពីឆ្នាំណាមក?

១ - ព្រោះអាស្រ័យដោយសេចក្ដីឧបត្ថម្ភ របស់ព្រះមហាថេរព្រះនាមមោគ្គលីបុត្ត និងព្រះបាទធម្មាសោកមហារាជ ជាព្រះចៅក្នុងសកលជម្ពូទ្វីប (ប្រទេសឥណ្ឌៀ) នាក្រុងបាតលីបុត្ត ទ្រង់បានចាត់ព្រះមហាថេរដែលមានសមត្ថភាព ឲ្យនិមន្តចេញទៅផ្សាយព្រះពុទ្ធសាសនា នៅប្រទេសនានា កាលពីពុទ្ធសតវត្សរ៍ទី ៣ ។ ព្រះមហាថេរអង្គណាត្រូវនិមន្តទៅប្រទេសណាដូចមានតទៅនេះ

១ ព្រះមោគ្គលីបុត្តតិស្សត្ថេរ បានចាត់ព្រះថេរានុត្ថេរៈ ឲ្យនិមន្តចេញទៅផ្សាយព្រះពុទ្ធសាសនានៅប្រទេសនានា ពីក្នុងពុទ្ធសតវត្សរ៍ ទី ៣ ។ ព្រះថេរៈណាត្រូវនិមន្តចេញទៅប្រទេសណាដូចមានតទៅនេះ៖

២ ព្រះមជ្ឈន្តិកត្ថេរ និមន្តទៅរដ្ឋកស្មីរ និងគន្ធារៈ (បានដល់រដ្ឋកស្មីរនិងគន្ធារៈក្នុងសម័យបច្ចុប្បន្ន ) :

៣ ព្រះមហាទេវត្ថេរ និមន្តទៅមហិសមណ្ឌល (បានដល់ទះទ្វេគោធាវរី ដែលបច្ចុប្បន្ននេះជាទីតាំងនៃរដ្ឋមៃសរ ) ;

៤ ព្រះរក្ខិតត្ថេរ និមន្តទៅវនវាសីប្រទេស (បានដល់ទេគ្គបុមបេស៍សព្វថ្ងៃនេះ ) ;

៥ ព្រះយោនកធម្មរក្ខិតត្ថេរ និមន្តទៅបរន្តបជនបទ (បានដល់រដ្ឋគុជរាតខាងជើងរបស់បុមបេស៍) ;

៦ ព្រះមហាធម្មរក្ខិតត្ថេរ និមន្តទៅឯមហារដ្ឋប្រទេស

៧ ព្រះមហារក្ខិតត្ថេរ និមន្តទៅយោនកប្រទេស (បានដល់បណ្ដាប្រទេសស៊ីរៈអេហ្ស៊ីប្ត ម៉ាសេដូន ក្រិក) ។ ល ។

៨- ព្រះមជ្ឈិមត្ថេរ និមន្តទៅហិមវន្តប្បទេស (បានដល់បណ្ដាប្រទេស ដែលតាំងនៅភ្នំហិមាល័យ ដូចជារដ្ឋនេប៉ាល់ ទីបេត៍ )

៩- ព្រះសោណត្ថេរ

www.facebook.com/7khmer
Fb page : Entertainment And Knowledge

១០- ព្រះឧត្តរត្ថេរ - ពីរអង្គនេះនិមន្តទៅឯសុវណ្ណភូមិ (ខ្ញុំយល់ថា គ្រានោះ ប្រទេសកម្ពុជាក៏នៅក្នុងភាគសុវណ្ណភូមិនែរ)

១១- ព្រះមហិន្ទត្ថេរ និមន្តទៅឯលង្កាទ្វីប (បានដល់ប្រទេសសិរីលង្កានាបច្ចុប្បន្ន នេះ) អ្នកប្រទេសនេះគេដឹងថា កាលព្រះមហិន្ទត្ថេរនិមន្តទៅគឺក្នុង ព.ស. ២៤៧ ក្នុងរជ្ជកាលនៃព្រះបាទទេវានំបិយតិស្សៈ ( អញ្ជើញមើលរូបទំព័រ១៥ )

## ២- ប្រទេសកម្ពុជាគ្រានោះមានទ្រង់ទ្រាយដូចម្តេច?

២- រឿងនេះខ្ញុំស្រាវជ្រាវរកពុំឃើញក្បួនតម្រាណាមួយបាននិយាយអំពីទ្រង់ទ្រាយប្រទេសកម្ពុជាក្នុងគ្រានោះឡើយ ។ ដល់មកគ្រាក្រោយបានឃើញសៀវភៅបារាំងមានចំណងជើងថា: " ប្រវត្តិប្រទេសកម្ពុជា ភាគទី ១ តែងដោយលោក សេអិល ម៉ា ឌ្រូល " មាននិយាយពីប្រទេសកម្ពុជាសម័យចិនឡា ក្នុងកំឡុងសតវត្សរ៍ទី ៧-៨ នៃគ្រិស្តសករាជ " ក្នុងរវាង ព.ស. ១.២៤០ - ១.៣៤០ " នេះតាមប្រភពនានា ដែលទទួលស្គាល់ថាប្រទេសចិនឡា ក្នុងសម័យនោះមានទំហំទ្រង់ទ្រាយធំប៉ុណ្ណេះ ឯយោបល់ខ្ញុំយល់ថាប្រទេសនេះមិនមែនទើបនឹងកើតក្នុងពុទ្ធសតវត្សរ៍ទី ១២ ឬ ១៣ នោះទេ គឺប្រមាណជាកើតតាំងពីពុទ្ធសតវត្សរ៍ទី ៣ មក បើដូច្នេះខ្ញុំអាចយល់ទៀតថា ប្រទេសកម្ពុជានេះក៏នៅក្នុងសុវណ្ណភូមិនែរ ។ ឯទំហំនឹងទ្រង់ទ្រាយប្រទេសកម្ពុជាសម័យចិនឡាដូចមានតទៅនេះ: ( អញ្ជើញមើលរូបទំព័រ១៦ )

## ៣- ព្រះថេរអង្គណាខ្លះដែលនិមន្តមកផ្សាយព្រះពុទ្ធសាសនាជាដំបូង ។ល។

៣ - រឿងនេះតាមគម្ពីរមហាវង្សពង្សាវតារលង្កាទ្វីបចែង បានសេចក្តីថា ព្រះសោណត្ថេរនឹងព្រះឧត្តរត្ថេរ និមន្តមកផ្សាយព្រះពុទ្ធសាសនាជាដំបូង ។ កាលព្រះថេរទាំងពីរអង្គនិមន្តមកកាន់សុវណ្ណភូមិនេះ អ្នកស្រុកឆ្ងើលសើចក្នុងកាន់អារុធបំងនឹងសម្លាប់

www.facebook.com/7khmer
Fb page : Entertainment And Knowledge

លោក ដោយគេសំគាល់ថាលោកជាមិត្តសំឡាញ់នឹងអារក្សទឹកដែលផ្ទាប់តែមកចាប់ទារក " កូនខ្ចី " ក្នុងភូមិយកទៅស៊ីរឿយៗ ។ ( រូបទំព័រ១៤ក្រោម )

១ – ព្រះសោណត្ថេរ　　　　២ – ព្រះឧត្តរត្ថេរ

៣ – ពពួកអ្នកស្រុក　　　　៤ – ពពួកអារក្សទឹក

ព្រះថេរៈថ្លែងថា លោកជាអ្នកបួសមានសីលមិនសម្លាប់មនុស្សនឹងសត្វទេ ទាំងសំដែងឥទ្ធិរិទ្ធិកំចាត់អារក្សទឹករត់ខ្ចាត់ខ្ចាយអស់ទៅ ។ អ្នកស្រុកកើតសេចក្ដីជ្រះថ្លា ជឿគោរពព្រះថេរៈទាំងពីរអង្គតាំងពីពេលនោះ ផ្ដាប់ផ្ដល់ឲ្យឈ្មោះកូនចៅរបស់ខ្លួន ដែលកើតក្នុងសម័យនោះថា " សោនុត្តរកុមារ សោនុត្តរកុមារ " តាមព្រះនាមព្រះថេរៈទាំងពីរអង្គ ។ លំដាប់ពីនោះព្រះថេរៈទាំងពីរអង្គ បានឱកាសនិមន្តផ្សាយព្រះពុទ្ធសាសនាក្នុងដែនសុវណ្ណភូមិ ពីប្រទេសមួយទៅប្រទេសមួយ ដែលនៅជិតខាងគ្នា ។

បើតាមពត៌មានខាងលើនេះ គេអាចយល់បានថា ព្រះថេរៈទាំងពីរអង្គដែលនិមន្តមកកាន់ដែនសុវណ្ណភូមិជាដំបូងនោះ គឺនិមន្តមកតាមផ្លូវជើងទឹកក្នុងរវាងពុទ្ធសតវត្សរ៍ទី៣ ។

## ៤ ធុរៈរបស់ព្រះពុទ្ធសាសនា មានប៉ុន្មានយ៉ាង ?

៤ មានពីរយ៉ាង :–

ក– គន្ថធុរៈ ធុរៈខាងការសិក្សាគម្ពីរបាលី

ខ– វិបស្សនាធុរៈ ធុរៈខាងការពិចារណា សភាវធម៌ឲ្យឃើញច្បាស់តាមការណ៍ពិត ។

## ៥ ពាក្យឱវាទដែលចេញពីគន្ថធុរៈ ដកស្រង់យ៉ាងខ្លី មានប៉ុន្មានយ៉ាង? បានសេចក្ដីដូចម្ដេចខ្លះ?

៥ មាន ៣ យ៉ាង :–

ក– សព្វបាបស្ស អករណំ កុំធ្វើអំពើអាក្រក់;

ខ– កុសលស្សូបសម្បទា ឲ្យធ្វើតែអំពើល្អ;

គ– សចិត្តបរិយោទបនំ ត្រូវញុំាងចិត្តឲ្យស្អាត ។ល ។

www.facebook.com/7khmer
Fb page : Entertainment And Knowledge

## ៦ បទពិចារណាក្នុងវិបស្សនាធុរៈ ដកស្រង់យ៉ាងខ្លី មានប៉ុន្មានយ៉ាង?

៦ មានច្រើនន័យ តែបើពោលយ៉ាងខ្លីមាន ៤ យ៉ាង :–

១– ទុក្ខសច្ច បានដល់ទុក្ខ ១២ កង;

២– សមុទយសច្ច បានដល់តណ្ហាបីប្រការ;

៣– និរោធសច្ច បានដល់ព្រះនិព្វាន;

៤– មគ្គសច្ច បានដល់ផ្លូវប្រកបដោយអង្គ ៨ ( អដ្ឋង្គិកមគ្គ ) ។ ល ។

## ៧ – ព្រះពុទ្ធសាសនា តាំងនៅបានអាស្រ័យដោយហេតុអ្វី

៧ – ព្រះពុទ្ធសាសនាតាំងនៅបាន ព្រោះអាស្រ័យហេតុ ៤ យ៉ាងៈ

១ – ព្រះមហាក្សត្រិយ៍ទាំងឡាយនៃប្រទេសកម្ពុជា ទ្រង់ជាពុទ្ធសាសនូបត្ថម្ភក៍ ជឿគោរពព្រះពុទ្ធសាសនាស្មើរតែរាល់ព្រះអង្គ ។

២ – ព្រះមហាថេរទាំងឡាយ បានយកព្រះទ័យទុកដាក់ក្នុងធុរៈព្រះពុទ្ធសាសនា ដូចជាការប្រែព្រះត្រៃបិដកជាដើម ។

៣ – ភិក្ខុសាមណេរទាំងឡាយ ខំយកព្រះទ័យប្រឹងប្រែងរៀនសូត្រគោរពធម៌វិន័យព្រះពុទ្ធសាសនាហើយឲ្យយត ១ ទៀ ។

៤– ពុទ្ធបរិស័ទ គ្រហស្ថបុរស–ស្ត្រី ជឿគោរពប្រតិបត្តិតាមទំនងព្រះពុទ្ធសាសនា

ហេតុទី ១ ដោយព្រះមហាក្សត្រិយ៍ទាំងឡាយនៃប្រទេសកម្ពុជាទ្រង់ជាពុទ្ធសាសនូបត្ថម្ភ ជឿគោរពព្រះពុទ្ធសាសនាៈ

ក – ក្នុងរជ្ជកាលទី ៧៩ នៃព្រះបាទសម្តេចព្រះហរិរក្សរាមាព្រះអង្គឌួង កាលពីព.ស.២៣៩១ គ.ស. ១៨៤៧ ស្តេចទ្រង់គង់នៅរាជធានីឧដុង្គមានជ័យ ទ្រង់

www.facebook.com/7khmer
Fb page : Entertainment And Knowledge

មានព្រះរាជបញ្ជាឲ្យប្រមូលនូវពុទ្ធវចនៈទាំងឡាយ មានគម្ពីរព្រះត្រៃបិដកជាដើម ហើយទ្រង់តាំងៈ

ព្រះមហាព្រហ្មមុនី " និល - ទៀង " ជាសម្ដេចព្រះសង្ឃរាជសង្ឃនាយកខាងគណៈមហានិកាយ ។

ព្រះវិមលធម្ម " ប៉ាន " បញ្ញាសីលោ ជាសម្ដេចព្រះសុគន្ធាធិបតីសង្ឃនាយកខាងគណៈធម្មយុត្តិ ហើយទ្រង់និមន្តសម្ដេចទាំងពីរព្រះអង្គ ឲ្យបង្រៀនព្រះត្រៃបិដកដល់សិស្សានុសិស្សទាំងឡាយ ។

ទាំងមន្ត្រីព្រះមហាក្សត្រិយ៍ក៏ទ្រង់ផ្ញើតបង្រៀនបាលីខ្លះក្នុងវេលាយប់ៗ ។ ល ។

១– ក្នុងរជ្ជកាលទី ៨០ នៃព្រះបាទសម្ដេចព្រះនរោត្ដម តាំងពី ព. ស. ២៤០៤ គ.ស. ១៨៦០ ព្រះអង្គក៏ទ្រង់ទំនុកបំរុងព្រះពុទ្ធសាសនាជាមតម្រាប់ព្រះបរមរាជបិតា លុះដល់ ព.ស. ២៤០៩ គ.ស. ១៨៦៥ ទ្រង់យាងមកគង់នៅរាជធានីក្រុងភ្នំពេញ ក៏នៅមានព្រះរាជានុញ្ញាតឲ្យបង្រៀនព្រះត្រៃបិដកក្នុងព្រះបរមរាជវាំងដូចរជ្ជកាលមុនដែរ ។ ល ។

គ– ក្នុងរជ្ជកាលទី ៨១ នៃព្រះបាទសម្ដេចស៊ីសុវត្ថិ តាំងពី ព. ស. ២៤៤៨ គ.ស. ១៩០៤ ក៏ទ្រង់ទំនុកបំរុងព្រះពុទ្ធសាសនាជាបដល់ ព.ស. ២៤៥២ គ.ស ១៩០៩ ទ្រង់ព្រះរាជានុញ្ញាតឲ្យបង្កើតសាលាបាលីនៅអង្គរវត្ត ហើយលើកសាលាបាលីមកតាំងនៅក្រុងភ្នំពេញពី ព.ស.២៤៥៨ គ.ស.១៩១៥ ។ ដល់ ព.ស២៤៦៨ គ.ស. ១៩២៥ ទ្រង់ព្រះរាជានុញ្ញាតឲ្យបង្កើតព្រះរាជបណ្ណាល័យកម្ពុជា ។ល។

ឃៈ– ក្នុងរជ្ជកាលទី ៨២ នៃព្រះបាទសម្ដេចព្រះស៊ីសុវត្ថិមុនីវង្ស តាំងពី ព. ស. ២៤៧០ គ–ស– ១៩២៧ ព្រះអង្គទ្រង់ទំនុកបំរុងព្រះពុទ្ធសាសនាដោយទ្រង់ព្រះរាជានុញ្ញាត :

– ឲ្យបង្កើតក្រុមជំនុំប្រែព្រះត្រៃបិដកពី ព.ស. ២៤៧២ គ.ស. ១៩២៨

– ឲ្យបង្កើតពុទ្ធសាសនបណ្ឌិតពី ព.ស. ២៤៧៣ គ.ស. ១៩៣០

www.facebook.com/7khmer
Fb page : Entertainment And Knowledge

- ឲ្យបង្កើតសាលាបាលីរងពី ព.ស. ២៤៧៥ គ.ស. ១៩៣២ ។ ល ។

ង - ក្នុងរជ្ជកាលទី ៨៣ នៃព្រះបាទសម្តេចព្រះនរោត្តមសីហនុវរ្ម័នពី ព.ស. ២៤៨៤ គ.ស ១៩៤១ ទ្រង់ជាពុទ្ធសាសនូបត្ថម្ភក៏

- ទ្រង់បានទទួលឧបសម្ប័ទ បួសជាភិក្ខុក្នុង ព.ស.២៤៩០ គ.ស.១៩៤៧ អស់រយៈវេលា ៣ ខែនឹង ហើយទ្រង់ព្រះរាជានុញ្ញាត៖

- ឲ្យបង្កើតសាលាធម្មវិន័យជាអាយុជីវិតនៃព្រះពុទ្ធសាសនាទូទៅគ្រប់វត្ត ពីក្នុង ព.ស. ២៤៩៣ គ.ស. ១៩៥០

- ឲ្យបង្កើតពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ ពីព.ស.២៤៩៧ គ.ស. ១៩៥៤ ហើយទ្រង់ប្រោសព្រះរាជទានដីសួនច្បារសួនចាស់ព្រមទាំងព្រះរាជទ្រព្យផ្ទាល់ព្រះអង្គចំនួនមួយលានប្រាំមួយសែនរៀល ឲ្យសង់មន្ទីរពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជផង ។ល។

ច - ក្នុងរជ្ជកាលទី ៨៤ នៃព្រះបាទសម្តេចព្រះនរោត្តមសុរាម្រិតនឹងសម្តេចព្រះ-មហាក្សត្រិយានីស៊ីសុវត្ថិមុនីវង្សកុសមនារីរ័តន៍សិរីវឌ្ឍនា ពី ព.ស. ២៤៩៨ គ-ស- ១៩៥៥ ទ្រង់ជាពុទ្ធសាសនូបត្ថម្ភក៏ទ្រង់មានព្រះរាជានុញ្ញាត៖

- ឲ្យផ្លាស់នាមសាលាបាលីជាន់ខ្ពស់ជា ពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត៖

- ឲ្យផ្លាស់នាមសាលាបាលីរងជាពុទ្ធិកបឋមសិក្សា

- ឲ្យរៀបចំកម្មវិធីបង្រៀនជាថ្មីសំរាប់សាលាទាំងពីរផ្នែក ឲ្យរីងរឹតតែប្រសើរឡើងផង ។ល។

ហេតុទី ២ ដោយព្រះមហាថេរទាំងឡាយបានយកព្រះទ័យទុកដាក់ក្នុងធុរៈព្រះពុទ្ធសាសនាយ៉ាងម្ចាំងម្ចាត់ ។ ជាប់ពី ព.ស. ២៤៧២ ទៅ ២៤៨២ គ.ស. ១៩២៩-១៩៤០ ព្រះមហាថេរនឹងលោកអាចារ្យទាំងអស់នេះបានទទួលធ្វើជាក្រុមជំនុំប្រែព្រះត្រៃបិដកជាភារៈដ៏ធ្ងន់ក្រៃលែង ដែលបណ្តាលជាហេតុធ្លាក់ឈាមគ្រាតែ-លោកអង្គខ្លះទទួលអនិច្ចធម្មទៅក៏សឹងមាន ។ តែទោះបីយ៉ាងនេះក៏ដោយ អស់លោកទាំងឡាយព្យាយាម ប្រែព្រះត្រៃបិដកពីបាលីមកជាភាសាខ្មែរលុះត្រាតែបានចប់សព្វគ្រប់

www.facebook.com/7khmer
Fb page : Entertainment And Knowledge

អស់ ដែលជាហេតុនាំឲ្យល្បីកិត្តិនាមទៅប្រទេសនានាបានសុំយកព្រះត្រៃបិដកប្រែនោះទៅធ្វើជាគំរូ មានប្រទេសភូមានិងឥណ្ឌៀជាដើម ។

ដូច្នេះយើងសូមនាំមកនូវគុណានុរូបសកុសលប្រគេន - ជូនដល់លោកទាំងឡាយដែលទទួលអនិច្ចធម្មទៅហើយក្ដី ដែលរស់នៅបានទាន់ពាក់កណ្ដាលព្រះពុទ្ធសាសនានេះក្ដី ដូចមានរាយនាមខាងក្រោមនេះ

- ព្រះមហាវិមលធម្មថោងព្រហ្មបណ្ឌិតោ ជាងហ្វាងសាលាបាលីជាន់ខ្ពស់ទី ១ វត្តឧណ្ណាលោម “លោកទទួលអនិច្ចធម្មទៅហើយ” ព្រះមហាថេរអង្គនេះមានគុណសម្បត្តិប្រសើរណាស់ លោកខិតខំលើកស្ទួយព្រះពុទ្ធសាសនាណាស់ ផុតអំណើះពីលោកទៅ ក៏មានព្រះមហាថេរានុត្ថេរៈទាំងឡាយបានចូលធ្វើជាក្រុមជំនុំប្រែព្រះត្រៃបិដក គឺៈ

១ សិរីសម្មតិវង្ស ល្វី-អែម វជិរប្បញ្ញោ សព្វថ្ងៃនេះជាព្រះធម្មលិខិតឧត្ដមប្រឹក្សា វត្តលង្កាជាអធិបតី

២ ព្រះឧត្ដមមុនី អ៊ុម-ស៊ួរ ធម្មវិនយរក្ខិតោ ជាអធិបតីរងលោកទទួលអនិច្ចធម្មទៅហើយ

៣ ព្រះមហាព្រហ្មមុនី អ៊ូ ចិតវីរិយោ វត្តស្វាយពពែ ជាអធិបតីរងក្រុមជំនុំ

៤ ព្រះសាសនសោភ័ណ ជួន-ណាត ជោតញ្ញាណោ សព្វថ្ងៃនេះជាសម្ដេចព្រះសង្ឃនាយកគណៈមហានិកាយ

៥ - ព្រះវិសុទ្ធិវង្ស ហួត - តាត វជិរប្បញ្ញោ អាចារ្យបង្រៀនសំស្ក្រឹតនៅសាលាបាលីជាន់ខ្ពស់ សព្វថ្ងៃនេះឡើងឋានៈជាព្រះពោធិវង្ស ជាងហ្វាងសាលាពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត

៦- ព្រះបាឡាត់សំវិជ្ជា មឿង មុនិត្ថេរោ

៧- ព្រះមហា សោម - ឈុន វិមលប្បញ្ញោ

www.facebook.com/7khmer
Fb page : Entertainment And Knowledge

៨- ” សោម - ឡុច សុធម្មលិខិតោ

៩- ” សេស បន្ទធម្មោ

១០- ព្រះគ្រូញាណសំវរ ឈឹម នេះគបញ្ញោ

១១- ព្រះអាចារ្យ ចាប - ពិន សុវណ្ណជោតោ

១២- ព្រះមហា ហួត តាតបណ្ឌិតោ

១៣- ព្រះអាចារ្យ ប៉ែន - សុខ ញាណសារោ

១៤- ” ហែម - ចៀវ ជោតញាណោ ១

១៥- ” ឈឹម - ស៊ុម សទ្ធម្មបញ្ញោ ១

១៦- ” គាំ - ខុំ លោកណបណ្ឌិតោ

១៧- ” សួ - ហាយ សុវណ្ណញាណោ ១

១៨- ” យូរ - អ៊ុន ឧត្តរញាណោ ១

១៩- ” អ៊ុក - ជា វជិរញាណោ ១

២០- ព្រះបាឡាត់ អ៊ុយ-ប៉ាង ខេមកោ

២១- ព្រះមុនីសុមេធា ឡុង-ជា វេរោ

២២- ព្រះបាឡាត់ កេត-តោ ចិត្តសីលោ

២៣- ព្រះអាចារ្យ ម៉ាង-នាង ធម្មកោសលោ

២៤- ” មៃ-យ៉ាន បណ្ឌិតវរោ

២៥- ” អែន-ប៉ង់ វិនយសត្ថា

២៦- ព្រះបាឡាត់ ហែម-ញឹម សុន្ទរោ

២៧- លោកមហា ថែម ឧបាសក

២៨- លោកអាចារ្យ ហុង- ឈា ឧបាសក

២៩- ” ង៉ែត-ហឹម ”

---

“១” សុំមើលក្នុងសៀវភៅថ្លែងគុណព្រះមហាថេរនេះក្នុង ព.ស. ២៤៧០ គ.ស. ១៩២៣

www.facebook.com/7khmer
Fb page : Entertainment And Knowledge

| | | | |
|---|---|---|---|
| ៣០- | " | ប៊ូ - ប៉ូ | " |
| ៣១- | " | យូរ | " |
| ៣២- | " | អ៊ុក-សេន | " |
| ៣៣- | " | ហ៊ំ- ហេង | " |
| ៣៤- | " | គិម-អាន | " |
| ៣៥- | " | នួន-នួង | " |
| ៣៦- | " | សេក-ឈុន | " |
| ៣៧- | " | អ៊ុប-រស់ | " |

ហេតុទី ៣ ដោយមានលោកភិក្ខុសាមណេរទាំងពីគណៈចំនួន ៦១.២០០ អង្គ គង់នៅវត្តទាំងឡាយចំនួន ២៨២០វត្ត គោរពប្រតិបត្តិតាមក្រិត្យវិន័យ គន្លងព្រះពុទ្ធសាសនា ដែលនាំឲ្យប្រទេសយើងមានកេរ្តិ៍ឈ្មោះជាប្រទេសអ្នកបួសដោយត្រឹមត្រូវ ។

ហេតុទី ៤ ដោយប្រជាជនខ្មែរប្រុស-ស្រី រាប់លាននាក់ជាពុទ្ធបរិស័ទ ជឿគោរពប្រតិបត្តិតាមឱវាទព្រះពុទ្ធអង្គ ហើយទ្រទ្រង់នូវយកក្នុងធុរៈព្រះពុទ្ធសាសនាដោយអាស្រ័យហេតុទាំង៤នេះជាដើមហើយ ទើបព្រះពុទ្ធសាសនាតាំងនៅបាន ។

នៅឱកាសធ្វើបុណ្យពាក់កណ្ដាលព្រះពុទ្ធសាសនា ខ្ញុំព្រះករុណា ខ្ញុំសូមបញ្ចប់ប្រវត្តិព្រះពុទ្ធសាសនាដ៏សង្ខេបនេះ ដោយឱនកាយគោរពចំពោះព្រះមហាក្សត្រិយ៍គ្រប់ព្រះអង្គដែលទ្រង់ជាពុទ្ធសាសនូបត្ថម្ភ ចំពោះព្រះថេរានុត្ថេរៈ ព្រមទាំងលោកអាចារ្យទាំងឡាយដែលបានទទួលធ្វើជាក្រុមជំនុំប្រែព្រះត្រៃបិដកលុះត្រាតែចប់ ចំពោះពុទ្ធបរិស័ទទាំងឡាយដែលប្រមូលកម្លាំងនូវយធុរៈព្រះពុទ្ធសាសនាឲ្យបានចំរើនរុងរឿងនៅក្នុងប្រទេសយើងជាល់ជាប់មកពាប់តាំងពីថ្ងៃដែលព្រះសោណត្ថេរនិងព្រះឧត្តរត្ថេរនាំសាសនាព្រះពុទ្ធសាសនាមកឲ្យយើងនៅលើកម្ពុជរដ្ឋរហូតដល់ថ្ងៃដែលយើងធ្វើបុណ្យ ព.ស.២៥០០ វស្សានេះ ។ ខ្ញុំព្រះករុណាខ្ញុំ សូមប្រតិស្ឋអធិដ្ឋាន សូមឲ្យព្រះពុទ្ធសាសនារស់នៅជាមួយនឹងពុទ្ធបរិស័ទទូទៅ ។ កាលបើពុទ្ធបរិស័ទទូទៅរស់នៅជិតបណា សូមឲ្យព្រះពុទ្ធសាសនារស់នៅជិតបនោះ កុំបីឃ្លៀងឃ្លាតឡើយ ។

www.facebook.com/7khmer
Fb page : Entertainment And Knowledge



ខាងឆ្វេងព្រះបាទធម្មាសោកមហារាជកំពុងសន្ទនានឹងព្រះមោគ្គលិបុត្ត
ដើម្បីចាត់ព្រះសង្ឃឲ្យនិមន្តចេញទៅផ្សាយព្រះពុទ្ធសាសនានៅនានាប្រទេស

King Asoka discussing on sending mission to spread Buddhism with Venerable Pras Moggaliputta



ព្រ[illegible]នឹងព្រះឧត្តរត្ថេរមកដល់សុវណ្ណភូមិ

www.facebook.com/7khmer
Fb page : Entertainment And Knowledge

# ព្រះថេរដែលនិមន្តទៅផ្សាយព្រះពុទ្ធសាសនាក្នុងទីផ្សេងៗ



១– ព្រះមោគ្គលីបុត្ត          ២– ព្រះមជ្ឈន្តិកត្ថេរទៅកស្មីរៈនិងគន្ធារៈ

៣– ព្រះមហាទេវត្ថេរទៅស្ទឹងគោធាវរី ជិតរដ្ឋម៉ៃសូរបច្ចុប្បន្ននេះ

៤– ព្រះរក្ខិតត្ថេរទៅរដ្ឋបំបៃ ៥– ព្រះយោនកធម្មរក្ខិតត្ថេរទៅទិសខាងជើងបំបៃ

៦– ព្រះមហាធម្មរក្ខិតត្ថេរទៅក្រុងមធុរដ្ឋ

៧– ព្រះមហាធម្មរក្ខិតត្ថេរទៅស៊ីរីអេហ្ស៊ីប ក្រិច

៨– ព្រះមហាមជ្ឈិមត្ថេរទៅភូមិភាគហេមពាន្ត គឺនេប៉ាល់និងទីបេត៍

៩– ព្រះសោណត្ថេរទៅសុវណ្ណភូមិ គឺប្រទេសកម្ពុជាបច្ចុប្បន្ននេះ

១០– ព្រះឧត្តរត្ថេរទៅសុវណ្ណភូមិ គឺប្រទេសកម្ពុជាបច្ចុប្បន្ននេះ

១១– ព្រះមហាមហិន្ទត្ថេរទៅកោះលង្កា

**Buddhist Mission to different countries.**

1. Prah Moggaliputta, Director of the group.
2. Prah Majjhantikathera, Kahmir and Gandhara.
3. Prah Mahádevatthera, the area contiguous to the Godávari river, site of present day state of Mysore.
4. Prah Rakkhitatthera, the State of Bombay.
5. Prah Yonakadhammarakkhitatthera, area north of Bombay.
6. Prah Mahádhammarakkhitatthera, area then known as Mahárath.
7. Prah Mahárakkhitatthera, Syria, Egypt, Greece.
8. Prah Mahámajjhimatthera, Himalayan area of Nepal and Tibet.
9. Prah Sonatthera, Suvannabhumi, present day Cambodia.
10. Prah Uttaratthera, Suvannabhumi, present day Cambodia.
11. Prah Mahindatthera, Ceylon in the 247th Year of the Buddhist Era during the reign of King Devánampiyatissa.

www.facebook.com/7khmer
Fb page : Entertainment And Knowledge

ព្រះរាជអាណាចក្រកម្ពុជាពេលដែលព្រះពុទ្ធសាសនាទើបផ្សាយមកដល់

Geographical limits of Cambodia during time of the introduction of Buddhism·




Cities

| | | | | | | | |
|---|---|---|---|---|---|---|---|
| 1 | Içanapura | 5 | Haripunjaya | 9 | Çreshthapura | 13 | Bhavapur |
| 2 | Wen Tan | 6 | Lavo | 10 | Çambhupura | 14 | Vyadhapı |
| 3 | Simhapura | 7 | Dvaravatia | 11 | Kauthara | 15 | Na Fou N |
| 4 | Giao Chi | 8 | Kamlangka | 12 | Indrapura | 16 | Kida (Kic |


www.facebook.com/7khmer
Fb page : Entertainment And Knowledge

# ព្រះរាជវង្ស

# THE ROYAL FAMILY



ព្រះបាទសម្ដេចព្រះហរិរក្សរាមា
ព្រះអង្គឌួង
Prah Ang Duong



ព្រះបាទសម្ដេចព្រះនរោត្ដម
Prah Norodom



ព្រះបាទសម្ដេចព្រះស៊ីសុវត្ថិ
Prah Sisowath



ព្រះបាទសម្ដេចព្រះស៊ីសុវត្ថិមុនីវង្ស
Prah Sisowath Munivong

www.facebook.com/7khmer
Fb page : Entertainment And Knowledge

## ព្រះរាជវង្ស

## ROYAL FAMILY



ព្រះបាទសម្តេចព្រះនរោត្តម សីហនុ
វរ្ម័ន

Prah Norodom Sihanouk



ព្រះបាទសម្តេចព្រះនរោត្តមសីហនុវរ្ម័ន
កាលទ្រង់ព្រះផ្នួស

King Sihanouk as Buddhist monk



ព្រះបាទសម្តេចព្រះនរោត្តមសុរាម្រឹត

Prah Norodom Suramarith



សម្តេចព្រះមហាក្សត្រិយានី

Prah Moha Kossamak

www.facebook.com/7khmer
Fb page : Entertainment And Knowledge

# សម្ដេចព្រះសង្ឃនាយកគណៈ ធម្មយុត្តិកនិកាយតាំងពីអតីតមកបច្ចុប្បន្ននេះ

## មាន៥ព្រះអង្គដូចខាងក្រោមនេះ

## CHIEF OF DHAMMAYUTH ORDER

**from origine to present time**



សម្ដេចព្រះសុគន្ធាធិបតី

បញ្ញាសីលោ "ប៉ាន"

Samdach Pras Sugandhadhipadey

« Pan »



សម្ដេចព្រះមង្គលទេពាចារ្យ

ភទ្ទន្ត "អៀម"

Samdach Pras Mongkuldebachar

« Eim »



សម្ដេចព្រះសុធម្មាធិបតី

ពុទ្ធតាគោ "អ៊ុង–ស្រី"

Samdach Pras Sudbammadipadey

« Ung_Srey »



សម្ដេចព្រះមង្គលទេពាចារ្យ

បញ្ញាទីបោ "ស៊ុក"

Samdach Pras Monkuldebachar « Souk »



សម្ដេចព្រះសុធម្មាធិបតី

ឥន្ទញ្ញាណោ "ភុល–ទេស"

Samdach Pras Sudhammadhipadey «Phoul-Tes»

www.facebook.com/7khmer
Fb page : Entertainment And Knowledge

## សម្តេចព្រះសង្ឃនាយកគណៈមហានិកាយតាំងពីអតីតមកបច្ចុប្បន្ននេះ

## មាន៤ព្រះអង្គដូចខាងក្រោមនេះ

# CHIEF OF MAHANIKAYA ORDER

**from origine to present time**



សម្តេចព្រះសង្ឃរាជ និល.ទៀង

Samdach Sankhareach «Nil-Tiang»



សម្តេចព្រះធម្មលិខិតតិន្នត្ថេរោ កែ.អ៊ុក

Samdach Pras Dhammalikkhit
» Ker-Ouk »



សម្តេចព្រះមហាសុមេធាធិបតី

ចន្ទត្ថេរោ ប្រាក់.ហ៊ិន

Samdach Pras Maha Sumedhadhipadey
« Prak-Hin »



សម្តេចព្រះមហាសុមេធាធិបតី

ជោតញ្ញាណោ ជួន.ណាត

Samdach Pras Maha sumedhadhipadey
« chuon-Nath »

www.facebook.com/7khmer
Fb page : Entertainment And Knowledge

# MEMBERS OF THE TRIPITAKA COMMITTEE



ព្រះវិមលធម្ម
“ថោង”
វត្តឧណ្ណាលោម ជាសាស្ដាចារ្យ
ឯកខាងបង្រៀនព្រះត្រៃបិដកជាន់
ដើម ។
Pras Nimolatham « Thong » (deceased)



ព្រះមហាព្រហ្មមុនី
“អ៊ូ”
វត្តស្វាយពពែ អធិបតីរងនៃក្រុម
ជំនុំប្រែព្រះត្រៃបិដក
Pras Maha Brahmamuni « Ou »



ព្រះឧត្តមមុនី
“អ៊ុមស៊ូ”
វត្តឧណ្ណាលោម អតីតអធិបតីរង
នៃក្រុមជំនុំប្រែព្រះត្រៃបិដក
Pras Uttamamuni « Oum-Sou »



សម្ដេចព្រះធម្មលិខិតឧត្តមប្រឹក្សា
វត្តលង្កា “ស៊ី-ឯម”
អតីតអធិបតីក្រុមជំនុំប្រែព្រះត្រៃ
បិដក
Samdach [illegible]



ព្រះពោធិវង្ស
វត្តវិហារសួគ៌? “ហួត-តាត”
ខាងហ្វាងពុទ្ធិកវិទ្យាល័យព្រះ
សុរាម្រិត
Pras Eodhivong « Huot-Tath »

www.facebook.com/7khmer
Fb page : Entertainment And Knowledge

# THE HISTORY OF BUDDHISM IN CAMBODIA

by

**SAM - NHEAN**

President of the Buddhist Association in Cambodia

**1957**

www.facebook.com/7khmer
Fb page : Entertainment  And Knowledge

We gratefully acknowledge the assistance of the United States Information Service in Cambodia, which helped make this book possible.

SAM NHEAN

10.000 copies
Printed in Phnom-Penh Cambodia
May 1, 1957

www.facebook.com/7khmer
Fb page : Entertainment And Knowledge

# FOREWORD

The Committee of Administration of the Buddhist Association in Cambodia, on the occasion of the celebration of the 2.500th year of the Buddhist era, has requested me to prepare this short study of the histo y of Buddhism in our country. It is for our own people and it is also for all those who come to celebrate this happy occasion with us or, united with us in spirit, celebrate it in their own lands.

I have been asked briefly to deal with the following questions :

1) When was Buddihsm introduced into Cambodia and under what circumstances?

2) What were the geographical limits of Cambodia at that time ?

3) Who were the monks who first preached Buddhism in this country ?

4) According to the Sacred Tripitaka what are the duties proper to Buddhism ?

5) What, in brief, are the principles derived from the Ganthadhura (learning stage) ?

6) What, in brief, are the principles derived from the Vipassanadhura (meditating stage) ?

7) What have been the causes responsible for the flourishing growth of Buddhism in Cambodia ?

www.facebook.com/7khmer
Fb page : Entertainment And Knowledge

The Committee of Administration of the Buddhist Association in Cambodia wishes these facts to be recalled to our minds in token of our gratitude to the monks who first came to Cambodia preaching Buddhism. On this important occasion, such gratitude unites us all in our thoughts of the Lord Buddha.

I wish to express my appreciation to Mr. Ang Kheao, Chief Cultural Affairs Assistant of the United States Information Service, American Embassy. Phnom-Penh, for his assistance in translating this study into English so that it can be made available to Buddhists in other countries.

Phnom-Penh, April 18, 1957.

SAM NHEAN

*President of the Buddhist Association in Cambodia*

www.facebook.com/7khmer
Fb page : Entertainment And Knowledge

## 1. When was Buddhism introduced into Cambodia and under what circumstances?

During the third century of the Buddhist era the King of India, named Dhammāsoka, who lived in the country then called Pataliputra, commissioned the learned and zealous monk Moggaliputra to send capable and holy monks to preach Buddhism in many surrounding lands. Eleven of these monks departed on their mission, two of them coming to the land now known as Cambodia. These were Prah Sonatthera and Prah Uttaratthera who went to Suvannabhumi, (see page 14-15)

## 2. What were the geographical limits of Cambodia at that time?

No extant documents are available concerning the geographical limits of Cambodia at that remote time. Our earliest source is a book entitled: *Histoire du Cambodge, 1ère Partie, Chronologie des Souverains Khmers jusqu'à la mi-XIVe s.*, by CL. Madrole, which deals with the area of Chenla during the Pre-Angkor peroid when present day Cambodia was part of that area, *viz.*, during the 7 th to the 8 th centuries A.D., or 1240 to 1340 of the Buddhist era. This book indicates the area covered by Cambodia as part of Chenla, as illustrated in the accompanying map. In the absence of any contradictory evidence it seems reasonable to assume that Cambodia was in existence during the third century of the Buddhist era and continued in existence until the 12th or 13th century of the Buddhist era as part of the area called Suvannabhumi.

## 3. Who were the monks who first preached Buddhism in this country?

According to the Scriptures of Mahavamsa in the History of Ceylon it was Prah Sonatthera and Prah Uttaratthera who first preached Buddhism in Suvannabhumi (present day Cambodia). The story is related that when these two monks first arrived in Suvannabhumi the people were much alarmed and armed themselves with weapons intending to kill the monks. These were accused of being

www.facebook.com/7khmer
Fb page : Entertainment And Knowledge

allied with the water *genii* who, according to belief, were responsible for the deaths of many children in the country (see illustration page 14-15).

The two monks declared that they were disciples of Buddha and were forbidden to harm or kill any living being, human or animal. In proof of this they performed miracles and banished the water *genii*. Consequently the people believed in their message and followed their teaching with such reverence that they even named their children «Sonattherakomar» (children of Sonatthera) in honor of the two monks. From that time on Prah Sonatthera and Prah Uttaratthera safely preached the message of Buddha within the whole area of Suvannabhumi. If this story is correct it seems likely that these first two monks came to Cambodia by some water route from India.

### 4. According to the Sacred Tripitaka what are the duties proper to Buddhism ?

The duties proper to Buddhism are performed in two stages :

*a.* Ganthadhura (Learning stage),

*b.* Vipassanādhura (Meditating and Right Thinking stage).

### 5. What, in brief, are the principles derived from the Ganthadhura (Learning stage) ?

The principles derived from the Ganthadhura (Learning stage) are threfold :

*a.* Sabbapāpassa akaranam (Avoid bad actions),

*b.* Kusolassopasampadā (Do only good actions),

*c.* Sacittapariyodapanam (Think only right thoughts).

### 6. What, in brief, are the Principles derived from the Vipassanādhura (Meditating Stage)?

These are interpreted in various ways but may be reduced to four ;

*a)* Dukkhasacca (Sorrows in twelve groups),

*b)* Samudayasacca (Passions in three groups),

*c)* Nirodhasacca (The state of Nirvana),

*d)* Maggasacca (The Eightfold Path).

www.facebook.com/7khmer
Fb page : Entertainment And Knowledge

## 7. What have been the causes responsible For The flourishing growth of Buddhism in Cambodia ?

The causes responsible for the flourishing growth of Buddhism in Cambodia are the following:

1. The support and example of the Royal family,
2. The scholarly achievement of the Tripitaka committee,
3. The zeal and example of the monks,
4. The devotion of the Cambodian people.

### 1. The support and example of the Royal Family

In the long history of Cambodia almost every king has devoutly believed in and supported Buddhism. Though we cannot treat of all of them here, we are able to point out the principal events contributing to the growth of Buddhism during the past hundred years:

*a)* **During the 79th Reign** — in 2391 B.E. (1847 a.d.) Prah Samdech Prah Harirakrama Prah Ang Duong, who reigned at the capital of Oudong Meanchey (Victory), ordered the collection of all Buddhist documents, including the Tripitaka. He further commissioned Prah Maha Brahmamuni Nil Tieng, Head of the Mahānikay Order, and Prah Vimaladhamma panna silo Samdech Prah Sugandhādhipati, Head of the Dhammayuth Order, to see that the Tripitaka was taught to the monks. In his leisure time the King himelf taught evening classes in Pali.

*b)* **During the 80th Reign** — when Prah Bat Samdech Prah Norodom began his reign in 2404 B.E. (1860 A.D.) he followed closely his father's example in supporting Buddhism. In 2409 B.E. (1865 A.D.), when the country's capital was transferred from Oudong to Phnom Penh, he ordered that Tripitaka classes be taught in the Royal Palace.

*c)* **During the 81st Reign** — in 2452 B.E. (1909 A.D.) Prah Bat Samdech Prah Sisowath ordered the opening of the Pali School at Ankor Wat. This school was transferred to Phnom Penh in 2458 B.E. (1915 A.D.) and in

www.facebook.com/7khmer
Fb page : Entertainment And Knowledge

2469 B.E. (1925 A.D.) the Royal Library of Cambodia was established.

*d)* **During the 82nd Reign** — which began in 2470 B.E. (1927 A.D.), Prah Bat Samdech Prah Sisowath Munivong ordered the establishment of the following :

i. The Committee for Translating the Tripitaka into the Cambodian language, in 2472 B.E. (1929 A.D.),

ii. The Buddhist Academy in 2473 B.E. (1930 A.D.),

iii. The Pali Schools in 2475 B.E. (1933 A.D.).

*e)* **During the 83rd Reign** — which began in 2484 B.E. (1941 A.D.), Prah Bat Samdech Prah Norodom Sihanouk Varman ordered the establishment of the following :

i. Monastic schools in every monastery in 2493 B.E. (1950 A.D.). These play a vital role in the growth of Buddhism.

ii. The Buddhist Prah Sihanouk Reach University in 2497 B.E. (1954 A.D.), for which he set aside the land and one million riels for the cost of construction. While he was King, Prah Bat Samdech Prah Sihanouk Varman was a monk during 2490 B.E. (1947 A.D.).

*f)* **During the 84th Reign** — which began in 2498 B.E. (1955 A.D.), Prah Bat Samdech Prah Norodom Suramarith and Prah Moha Kossamak Neary Reat Sirivadhana have been responsible for the following :

i. Changing the Pali Superior School in Phnom-Penh into the Lycee Bouddhique Prah Suramarith,

ii. Changing the provincial Pali School into Buddhist Primary Schools,

iii. Improving the curricula of all these schools.

## 2. The Scholarly Achievement of the Tripitaka Committee

From 2472 B.E. (1929 A.D.) until 2482 B.E. (1940 A.D.) a group of outstanding monks and laymen worked tirelessly on the monumental task of translating the Tripitaka into the Cambodian language. This extremely difficult undertaking even undermined the health of some of the monks, who succumbed during the course

www.facebook.com/7khmer
Fb page : Entertainment And Knowledge

of their labors. Its completion has spread the good name of Buddhism in Cambodia to other nearby countries like Burma and India where the Cambodian translation is being used as a model for similar endeavors.

It is fitting, therefore, that we pay tribute to all those, living and dead, who contributed to this great work, *viz.*:

Prah Sirisamadhivamsa Louis Em Vajirappañño, at the present time Prah Dhammalikhit, Member of the Advisory Council of the Langka Monastery..... Committee President.

Prah Uttammuni Oum Sou Dhammavinayarakkhito.... . Committee Vice-president (deceased).

Prah Maha Brahmamuni Ou Thitaviriyo, Svay Pope Monastery ....... Commitee Vice-president

**Committee Members**

Prah Sasanasobhan Chuon Nath Jotaññāno (now Head of the Mahanikay Order),

Prah Visuddhivamsa Huot Tath Vajirappañño, Professor of Sanskrit, Superior School of Pali (now Prah Bodhivamsa, Director of the Lycee Bouddhique Prah Suramarith),

Prah Balat Samvijja Moeung Munithero,

Prah Maha Som Chhun Vimalappañño,

Prah Maha Som Loch Sudhammalikhito,

Prah Maha Ses Candadhammo,

Prah Garu Ñanasamvara Chhoeun Jotappañño,

Prah Acary Chap Pin Suvannajoto,

Prah Maha Huot Nagapandito,

Prah Acary Pen Sok Ñanasaro,

Prah Acary Hem Chieu Jotaññāno,

Prah Acary Chhim Soum Saddhammappañño,

Prah Acary Keam Doum Sobhanapandito,

Prah Acary So Hay Savaddhaññāno,

Prah Acary You Oun Uttaraññāno,

Prah Acary Ouk Chea Vajiraññāno,

Prah Balat Ony Pang Khemako,

www.facebook.com/7khmer
Fb page : Entertainment And Knowledge

Prah Munisumedha Song Chea Revato,
Prah Balat Khet To Thitasilo,
Prah Acary Mang Neang Dhammakusalo,
Prah Acary Me Pan Panditavaro,
Prah Acary Enn Pang Vinayasattha,
Prah Balat Hem Nhim Sundaro,
Messrs. Maha Them, Hong Chhea, Nget Him, Bou Po, You, Ouk Sen, Ham Heng, Kim An, Nuong Duong, Seh Chhun, and Ouch Ros,

### 3. The zeal and example of the Monks

The growth of Buddhism in Cambodia has followed along orthodox lines of doctrine and discipline and at the present time our country enjoys an enviable reputation for the sanctity of its monks and their devotion to Buddhist observances. These monks, both Bhikhus and Samaneras of the Mahanikay and the Dhammayuth Orders, number 61,200 living in 2,820 monasteries.

### 4. The devotion of the Cambodian People

Cambodia is a Buddhist country and its inhabitants believe firmly in Buddhism and follow the Buddha's way of life.

On the occasion of the celebration of the 2,500th Year of the Buddhist era, I bring this short study to a close by honoring all those who have contributed to the glory of Buddhism in Cambodia up until the present day: zealous kings, holy monks, devoted laymen and women. For 2,200 years, ever since Prah Sonatthera and Prah Uttaratthera brought the message of Buddha to this land in the third century of the Buddhist era, Buddhism has flourished here. May its spiritual power continue to teach us how to live in joy and harmony, with justice and with strength, following the high ideals of right thinking and of right acting. May the growth of Buddhism in the last half of the Buddhist era bring to Cambodia and to the whole world glory, prosperity, freedom and contentment.

www.facebook.com/7khmer
Fb page : Entertainment And Knowledge